សប្តាហ៍ទី
11

រឿងយ៉ាកុប ៣

ព្រះជាម្ចាស់គង់នៅជាមួយយ៉ាកុប!

ព្រះជាម្ចាស់គង់នៅជាមួយយ៉ាកុប!

រឿងក្នុងព្រះគម្ពីរ

យ៉ាកុបបាននៅម្នាក់ឯងនៅមាត់ទន្លេ។មានបុរសម្នាក់បានមករកលោកហើយបោកចំបាប់ជាមួយយ៉ាកុបរហូតដល់ភ្លឺ។

យ៉ាកុបបានខំប្រឹងអស់ពីកម្លាំងដើម្បីយកឈ្នះ ប៉ុន្តែបុរសនោះមិនងាយអស់កម្លាំងឡើយ។

ទីបំផុតបុរសនោះបានវាយចំចង្កេះរបស់យ៉ាកុប។ យ៉ាកុបបានដើរខ្ទើចៗ ប៉ុន្តែលោកបានទទួលពរពីបុរសនោះ ហើយបានកើតជាថ្មីក្លាយជាមនុស្សរបស់ព្រះ។

អត្ថបទគម្ពីរ៖
[លោកុប្បត្តិ៣២:២២-៣០]

សមិទ្ធផលសម្រេច



វត្ថុបំណង

- ស្វែងយល់រឿងដែលយ៉ាកុបបោកចំបាប់ជាមួយទេវតា។
- ជឿជាក់ថាព្រះជាម្ចាស់គង់នៅជាមួយយ៉ាកុប។
- ប្រើប្រាស់អេប៉ុង និងសំឡីក្បារត្រចៀកដើម្បីធ្វើស្នាដៃសិល្បៈ។

សម្ភារៈ


គំនូសព្រាង (យ៉ាកុប-ទេវតា)


ក្រដាសរឹង


កូលំរពណ៌ទឹក


អេប៉ុង

សំឡីក្បារត្រចៀក


ហ្វឺតខ្មៅ


ក្តារលាយពំណ៌


ក្រដាស់សើម

របៀបធ្វើ

1 រៀបចំគំនូសព្រាង



ប្រើប្រាស់គំនូសព្រាងរបស់គ្រូដើម្បីកាត់រូបយ៉ាកុប និងទេវតា។

2 លាបពណ៌ផ្ទៃខាងក្រោយ



ប្រើប្រាស់អេប៉ុងដើម្បីលាបមេឃ និងដីជាមួយពណ៌ងងឹត។

3 បន្តែមផ្កាយដោយការលាស់ពណ៌



ប្រើសំឡីក្បារត្រចៀកជ្រលក់ក្នុងពណ៌ស, ផ្ទៃមេឃស្រាលឬលឿងរួចរលាស់វាបង្កើតជាផ្កាយ។

4 គូរផ្កាយបន្តែម



ប្រើសំឡីក្បារត្រចៀកជ្រលក់ក្នុងពណ៌លឿង ដើម្បីគូរផ្កាយបន្តែម។

5 គូររូបព្រះចន្ទ



ប្រើពណ៌លឿងដើម្បីគូររូបព្រះចន្ទ ហើយតុបតែង។

6 ការសម្រេចសមិទ្ធផល



បិទរូបយ៉ាកុប និងទេវតា រួចតុបតែងសម្លៀកបំពាករបស់ពួកគាត់ដោយប្រើហ្វឺត និងកូលំរទឹកពណ៌

Tip សម្រាប់ការលេង

- និយាយពីរបៀបដែលយ៉ាកុបអធិស្ឋាន ហើយមិនបោះបង់។
- តស៊ូសាកល្បងអធិស្ឋានជាមួយគ្នាដូចយ៉ាកុប ដោយអរព្រះគុណព្រះអង្គសម្រាប់ជំនួយរបស់ទ្រង់។
- សរសេរ ឬគូរការអធិស្ឋានរបស់អ្នកនូវអ្វីដែលអ្នកសុំព្រះអង្គដើម្បីប្រទានដល់អ្នកដូចទ្រង់ប្រទានពរដល់យ៉ាកុប។
- ចែករំលែងពីរបៀបដែលព្រះជាម្ចាស់ប្រទានពរដល់អ្នកជាមួយមិត្តភក្តិរបស់អ្នក។



របៀបធ្វើការលាស់ពណ៌



1. ដាក់ពណ៌បន្តិចលើសំឡីក្បារត្រចៀក។
2. កាន់វា និងរលាស់ថ្មមៗទៅលើក្រដាស។
3. សាកល្បងប្រើប្រាស់ពណ៌ផ្សេងៗ ដើម្បីបង្កើតផ្កាយជាច្រើន។

កុំភ្លេចគ្របការពារសម្លៀកបំពាក់ និងតុរបស់អ្នក។

Tip សម្រាប់គ្រូ

- សូមប្រាប់កុមារអំពីការជួបគ្នាដ៏ពិសេសរបស់យ៉ាកុបជាមួយព្រះជាម្ចាស់។
- លើកទឹកចិត្តកុមារឱ្យមានអារម្មណ៍ដឹងពីក្តីស្រឡាញ់ និងជំនួយរបស់ព្រះជាម្ចាស់។
- សូមសរសើរការខិតខំប្រឹងប្រែង និងស្នាដៃច្នៃប្រឌិតរបស់ពួកគេ។
- សូមរំលឹកពួកគេថា ព្រះជាម្ចាស់តែងតែគង់នៅជាមួយយើង និងប្រទានពរដល់យើងជានិច្ច។